# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងព័ត៌មាន**

លេខ ១១២.ប្រក....ព.ម

## ប្រកាស

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨៩៥/០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី របបសារព័ត៌មាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន

-បានឃើញអនុក្រឹត្យលេខ ៧០/ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន

-បានឃើញអនុក្រឹត្យលេខ ៧១/អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន

-យោងប្រកាសអន្តរក្រសួងលេខ២៥៦៣.ណ.ចបព.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ រវាងក្រសួងព័ត៌មាន ជាមួយក្រសួងពាណិជ្ជកម្ម

-យោងប្រកាសលេខ ០៨៥ ប្រ.ក ព.ម ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤ ស្ដីពី ការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន របស់ក្រសួងព័ត៌មាន

-វិញ្ញាបនបត្រចុះបញ្ជីលេខ (No) MOC-00037533 ពណ.ចបព ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ របស់ក្រសួងពាណិជ្ជកម្ម

-យោងពាក្យស្នើសុំបើកអាជីវកម្មគេហទំព័រឈ្មោះ "www.freenewscambod.com" ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ របស់លោក សរ រដ្ឋា

-យោងតាមតម្រូវការចាំបាច់

## <u>សម្រេច</u>

**ប្រការ១**:-អនុញ្ញាតឱ្យលោក សរ រដ្ឋា សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណបណ្ណលេខ ០១០៥៦៨០២៣ (០១) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ មានអាសយដ្ឋាននៅផ្ទះលេខ៥៤៦ ភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល ជាម្ចាស់សហគ្រាស សរ រដ្ឋា ញូស៍ ផ្សព្វផ្សាយតាមរយៈ៖

-គេហទំព័រឈ្មោះ "www.freenewscambod.com"

-មានអាសយដ្ឋានទីស្នាក់ការនៅផ្ទះលេខ៥៤៦ ភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

**ប្រការ២**:រាល់ដំណើរការផ្សាយ និងមាតិកាផ្សព្វផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ បទប្បញ្ញត្តិច្បាប់ ច្បាប់ស្ដីពីរបបសារព័ត៌មាន ច្បាប់ស្ដីពីកម្មសិទ្ធិបញ្ញា ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន បទបញ្ជា កិច្ចសន្យា និងសេចក្ដីណែនាំនានា ពាក់ព័ន្ធវិស័យព័ត៌មាន និងសោតទស្សន៍ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣**: ករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤**: ប្រកាសនេះមានសុពលភាពរយៈពេល ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៥**: នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ប្រធានមន្ទីរព័ត៌មានខេត្តកណ្ដាល សាមីខ្លួន និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃ ពុធ ៨រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**នេត្រ ភក្ត្រា**

<u>ចម្លងជូន</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងពាណិជ្ជកម្ម

  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ